00329140

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 19 / 05 / 2009
ម៉ោង (Time/Heure) : 13:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A. [signature]

## កំណត់ហេតុជាលាយលក្ខណ៍អក្សរ
## នៃដំណើរការនីតិវិធីនៃសវនាការលើអង្គសេចក្តី
## ក្នុងសំណុំរឿងលេខ ០០១

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសង

ឯកសារប្រាកដជាប្រើប្រាស់តាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 22 / 05 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

ថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០០៩-ថ្ងៃទីដប់បី

សាធារណៈ

រៀបចំដោយ: សែ គុលវុឌ្ឍី និង Matteo CRIPPA

| កំណត់ហេតុអ្នកចូលរួម |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម ធូ មណី |
| ចៅក្រមបម្រុង៖ ចៅក្រម យូរ ឧត្តរា (បម្រុង) និង ចៅក្រម Claudia FENZ (បម្រុង) |
| ក្រឡាបញ្ជី៖លោក Crippa MATTEO,លោកស្រី សែ គុលវុឌ្ឍី,កញ្ញា Natacha Wexels-Riser លោក ឌុច ផារី |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក តាន់ សេណារ៉ុង, លោក Alexander Bates, លោក ពេជ្រ សម្បត្តិ,លោក ប៉ាក ចន្ទលីណូ,លោក Stuart Ford |

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

| |
|---|
| ជនជាប់ចោទ៖ កាំង ហ្គេកអ៊ាវ ហៅ ឌុច |
| មេធាវីជនជាប់ចោទ៖ លោក François Roux,លោក ការ សាវុត្ថ, លោកស្រី Heleyn Unac,លោក ចាន់ រ៉ាវុធ,កញ្ញា Virginie CHARPENTIER។ |
| មេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖លោក គង់ ពិសី,លោក យុង ផានិត, លោក ហុង គីម សួន,កញ្ញា Silke Studzinsky,កញ្ញា ទី ស្រីនណា,កញ្ញា ម៉ុច សុវណ្ណារី,លោក Philippe Canonne,លោក Alain Werner |
| មន្ត្រីតុលាការ/អង្គភាពគ្រប់គ្រងតុលាការ៖ លោក សាន់ រ៉ាដា |
| ផ្នែកផ្សេងៗ៖ លោកស្រី Maryvonne Moussounda Maniacky,លោកស្រី Julie Masse,លោក ឡាយ ណារ៉ា,លោក Pierre Cozette |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃ ទី ២៨ ខែមេសា ឆ្នាំ ២០០៩ ព្រឹក | ចាប់ផ្តើមម៉ោង៖ ០៩.១០ | បញ្ចប់ម៉ោង៖ ១៦.៣០ |
| សម្រាកព្រឹក | ចាប់ផ្តើមម៉ោង៖១០.៣០ | បញ្ចប់ម៉ោង៖ ១១.០០ |
| សម្រាក អាហារថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖១២.០៥ | បញ្ចប់ម៉ោង៖១៣.៣៥ |
| សម្រាកល្ងាច | ចាប់ផ្តើមម៉ោង៖ ១៤.៤៥ | បញ្ចប់ម៉ោង៖ ១៥.២០ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | **៤ ម៉ោង និង ៤៥នាទី** |

**<u>កិច្ចដំណើរការនីតិវិធី៖</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| សេចក្តីសម្រេចផ្ទាល់មាត់ទាក់ទងនឹងសិទ្ធិរបស់ភាគីក្នុងការពិភាក្សាជាមួយជនជាប់ចោទក្រៅពីសវនាការ | អង្គជំនុំជម្រះ | ៩.១០ | ៩.១៥ |
| បន្តតាំងសំណួរទៅជនជាប់ចោទទាក់ទងនឹងការបង្កើតមន្ទីរស២១ និងគុកតាខ្មៅ ដោយអង្គជំនុំជម្រះ | អង្គជំនុំជម្រះ | ៩.១៥ | ១០.៣០ |
| សំណើទាក់ទងនឹងការកំណត់កាលបរិច្ឆេទនៃដំណើរការសវនាការ | មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ | ១១.០០ | ១១.១០ |

កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃដំណើរការនីតិវិធីនៃសវនាការលើអង្គសេចក្តី– ថ្ងៃទី ២៨ខែមេសា ឆ្នាំ ២០០៩

ឯកសារសាធារណៈ

| | | | |
|---|---|---|---|
| សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី៣ ទាក់ទងនឹងបញ្ហាផ្សេងៗដែលត្រូវការសម្រេច | មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី៣ | ១១.១០ | ១១.១៥ |
| ការតាំងសំណួរទៅជនជាប់ចោទទាក់ទងនឹងការបង្កើតមន្ទីរស២១ និង គុកតាខ្មៅដោយសហព្រះរាជអាជ្ញា | សហព្រះរាជអាជ្ញា | ១១.១៥ | |
| សេចក្តីសម្រេចដោយផ្ទាល់មាត់ទាក់ទងនឹងពាក្យ សុំរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ ស្នើសុំឱ្យចេញដីកាកែតម្រូវទៅលើអត្តសញ្ញាណនៃការដាក់ឯកសារ | អង្គជំនុំជម្រះ | ១៣.៣៥ | ១៣.៣៥ |
| សេចក្តីសម្រេចដោយផ្ទាល់មាត់ទាក់ទងនឹងការកំណត់កាលបរិច្ឆេទនៃដំណើរការសវនាការ | អង្គជំនុំជម្រះ | ១៣.៣៥ | ១៣.៤០ |

<u>**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធី៖**</u>

<u>**បន្តតាំងសំណួរទៅជនជាប់ចោទទាក់ទងនឹងការបង្កើតមន្ទីរស២១ និងគុកតាខ្មៅ ដោយអង្គជំនុំជម្រះ**</u>

- អង្គជំនុំជម្រះបានបន្តតាំងសំណួរទៅជនជាប់ចោទទាក់ទងនឹងការបង្កើតមន្ទីរស២១ និងគុកតាខ្មៅ

<u>**សំណើទាក់ទងនឹងការកំណត់កាលបរិច្ឆេទនៃដំណើរការសវនាការ**</u>

- មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ បានស្នើសុំឱ្យអង្គជំនុំជម្រះធ្វើការបញ្ជាក់ពីការកំណត់កាលបរិច្ឆេទនៃដំណើរការសវនាការទៅថ្ងៃខាងមុខទៀត។ អង្គជំនុំជម្រះបានឆ្លើយតបចំពោះសំណើនេះថានឹងចេញនូវការកំណត់កាលបរិច្ឆេទនៃដំណើរការសវនាការលំអិតសម្រាប់ខែឧសភា និងមិថុនា ២០០៩ នៅមុនពេលការបញ្ចប់នៃសប្តាហ៍នេះ ។
- សហមេធាវីការពារក្តីអន្តរជាតិ លោក François Roux បានជូនដំណឹងថា គាត់នឹងអវត្តមានពីដំណើរការសវនាការនៅចុងសប្តាហ៍នេះ ដោយសារត្រូវចូលរួមសវនាការនៅតុលាការពិសេសសម្រាប់ប្រទេសលីបង់។

**សំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី៣ ទាក់ទងនឹងបញ្ហាផ្សេងៗដែលមានព្យួរការសម្រេច**

- មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី៣ បានស្នើឱ្យអង្គជំនុំជម្រះកំណត់នូវវិធានទាក់ទងនឹងបញ្ហាផ្សេងៗដែលបានព្យួរការសម្រេចដែលមានការមិនទទួលយកនូវឯកសារផ្សេងៗដែលធ្វើឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងភាពមិនត្រឹមត្រូវនៃសេវាកម្មបកប្រែភាសា។
- អង្គជំនុំជម្រះបានចង្អុលបង្ហាញថា អង្គជំនុំជម្រះនឹងធ្វើការពិភាក្សានៅក្នុងអំឡុងពេលនៃការសម្រាកនេះទៅលើបញ្ហា នៃការមិនទទួលយកនូវឯកសារផ្សេងៗរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ប៉ុន្តែដោយសារតែមិនទាន់មានសេចក្តីសម្រេចពេញលេញនោះ អង្គជំនុំជម្រះបានសម្រេចថានឹងប្រកាសសេចក្តីសម្រេចនេះនៅសប្តាហ៍ទី៣ បន្ទាប់ពីថ្ងៃឈប់សម្រាកក្នុងខែឧសភា ឆ្នាំ២០០៩។ ដោយឡែកចំពោះបញ្ហានៃភាពមិនត្រឹមត្រូវនៃសេវាកម្មបកប្រែភាសា អង្គជំនុំជម្រះបានជូនដំណឹងទៅភាគីទាំងអស់ថា អង្គជំនុំជម្រះនឹងពិភាក្សាជាមួយនឹងការិយាល័យរដ្ឋបាល។

**ការតាំងសំណួរទៅជនជាប់ចោទទាក់ទងនឹងការបង្កើតមន្ទីរស២១ និងគុកតាខ្មៅ ដោយសហព្រះរាជអាជ្ញា**

- សហព្រះរាជអាជ្ញាបានតាំងសំណួរទៅជនជាប់ចោទទាក់ទងនឹងការបង្កើតមន្ទីរស២១ និង គុកតាខ្មៅ
- សហព្រះរាជអាជ្ញាបានយោងទៅលើឯកសារលេខ E5/2.1, D58/II ឧបសម្ព័ន្ធ ២៤ និង E5/2.9.

**កំណត់ហេតុនៃដំណើរការនីតិវិធី វិធាន ៨៧៖**

| លេខយោង | ឈ្មោះ/សេចក្តីអត្ថាធិប្បាយ | ផ្សេងៗ |
|---|---|---|
| E3/24 | ចម្លើយសារភាពរបស់ អ៊ុំ សឿន | D58/II ឧបសម្ព័ន្ធ២៤ |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

១-អង្គជំនុំជម្រះសម្រេចបដិសេធសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ ដែលបានស្នើដោយផ្ទាល់មាត់កាលពីថ្ងៃទី២៧ ខែមេសា ឆ្នាំ ២០០៩ ដែលថាក្នុងអំឡុងពេលនៃការតាំងសំណួរទៅជនជាប់ចោទ គ្មានភាគីណាមួយ រួមទាំងមេធាវីការពារក្តី អាចប្រឹក្សាជាមួយជនជាប់ចោទអំពីចម្លើយដែលត្រូវផ្តល់ក្នុងអំឡុងពេលសវនាការបាននោះទេ ដោយឈរលើគោលការណ៍ថាមស្តង់ដារអន្តរជាតិ



TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE C C C E T C

មិនបានកំណត់អំពីសិទ្ធិរបស់មេធាវីការពារក្តីក្នុងការប្រឹក្សាជាមួយជនជាប់ចោទគ្រប់ពេលវេលាទាំងអស់ក្នុងអំឡុងពេលនៃដំណើរការសវនាការទេ។

២-អង្គជំនុំជម្រះបានទទួលយកពាក្យសុំរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទី១ ដែលស្នើឱ្យអង្គជំនុំជម្រះបង្គាប់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីគ្រប់ក្រុមទាំងអស់កែតម្រូវអត្តសញ្ញាណនៃការដាក់ឯកសារដែលមាននៅក្នុងឯកសារលេខE45 ។

៣-អង្គជំនុំជម្រះបានចង្អុលបង្ហាញថាដំណើរការសវនាការនឹងត្រូវផ្អាកចាប់ពីថ្ងៃទី ០១ ដល់ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០០៩ ក៏ដូចជាពីថ្ងៃទី ២៧ ដល់ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០០៩ ដោយសារតែសាលសវនាការត្រូវបានប្រើប្រាស់ដោយអង្គបុរេជំនុំជម្រះ ។ អង្គជំនុំជម្រះក៏បានចង្អុលបង្ហាញផងដែរថាដំណើរការសវនាការនឹងបន្តទៅរយៈពេលដែលមានពីខែមិថុនា ទៅខែសីហា ឆ្នាំ២០០៩។

៤-ដីកាបង្គាប់ឱ្យនាំជនជាប់ចោទទៅមន្ទីរឃុំឃាំង និងនាំគាត់ត្រឡប់មកវិញនៅថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៩ ។

**<u>ដីកាសម្រាប់ការលើកពេលសវនាការ៖</u>**

ការពន្យាពេលសវនាការ៖ សវនាការនឹងបន្តទៅថ្ងៃពុធ ទី ២៩ ខែមេសា ឆ្នាំ ២០០៩ វេលាម៉ោង ៩.០០ព្រឹក ។

ភ្នំពេញ, ថ្ងៃទី ២០ ខែឧសភា ឆ្នាំ ២០០៩

| ក្រឡាបញ្ជី | ក្រឡាបញ្ជី |
|---|---|
| **សែ គុល ធុឌ្ឍី** | **Matteo CRIPPA** |

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C • C E T C